ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

THE GARMENT MANUFACTURERS ASSOCIATION IN CAMBODIA (GMAC)
IN
THE SECRETARIAT
No :....546.....
Date:06.01.14 Time:10:00
For :....GMAC.....

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ :...007/14...ក.ប/ស.ណ.ន

សេចក្តីណែនាំ
ការអនុវត្តប្រកាសលេខ ៣១៧ ក.ប/ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការដំឡើងប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិត ផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើង និងការផ្តល់អត្ថប្រយោជន៍ផ្សេងៗ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបដល់អង្គការសហជីពគ្រប់ថ្នាក់ សមាគមនិយោជក កម្មករនិយោជិត និងនិយោជកនៃរោងចក្រ សហគ្រាស គ្រឹះស្ថាន ផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើងទាំងអស់ ត្រូវអនុវត្តតាមសេចក្តីណែនាំដូចខាងក្រោម៖

I.ការផ្តល់ប្រាក់ឈ្នួលអប្បបរមា

១-កំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតសាកល្បង ចាប់ពី ១ ខែ ទៅ ៣ ខែ ចំនួន ៩៥ (កៅសិបប្រាំ) ដុល្លារក្នុងមួយខែ (ប្រាក់ឈ្នួលអប្បបរមាបច្ចុប្បន្ន ៧៥ ដុល្លារបូកប្រាក់ដំឡើងចំនួន ២០ ដុល្លារ ស្មើនឹង ៩៥ ដុល្លារ)។ ចប់រយៈពេលសាកល្បង កម្មករនិយោជិតពេញសិទ្ធិត្រូវទទួលបានប្រាក់ឈ្នួលអប្បបរមាចំនួន ១០០ (មួយរយ) ដុល្លារក្នុងមួយខែ (ប្រាក់ឈ្នួលអប្បបរមាបច្ចុប្បន្ន ៨០ ដុល្លារបូកប្រាក់ដំឡើងចំនួន ២០ ដុល្លារ ស្មើនឹង ១០០ ដុល្លារ)។

២-ចំពោះកម្មករនិយោជិតដែលទទួលប្រាក់ឈ្នួលគិតតាមបរិមាណផលិតផល(ដេរស៊ីបុង) ត្រូវទទួលបានប្រាក់ឈ្នួលតាមទិន្នផលជាក់ស្តែងដែលធ្វើបាន។ បើទិន្នផលការងារទទួលបាននោះលើសពីចំនួនប្រាក់ឈ្នួលដែលមានចែងក្នុងចំណុចទី១ខាងលើ ត្រូវទទួលតាមការលើសនោះ។ ប្រសិនបើទាបជាង និយោជកត្រូវបន្ថែមឱ្យគ្រប់ចំនួន ៩៥ (កៅសិបប្រាំ) ដុល្លារក្នុងមួយខែ សម្រាប់

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

កម្មករនិយោជិតធ្វើការសាកល្បង និងចំនួន ១០០ (មួយរយ) ដុល្លារក្នុងមួយខែ សម្រាប់កម្មករនិយោជិតពេញសិទ្ធិ។

៣-ចំនួនទឹកប្រាក់ដែលត្រូវបានដំឡើងចំនួន ២០ (ម្ភៃ) ដុល្លារ ត្រូវបន្ថែមជូនកម្មករនិយោជិតគ្រប់ៗគ្នា លើប្រាក់ឈ្នួលដែលកំពុងទទួលបាន។

៤-ការផ្តល់ប្រាក់ឈ្នួលអប្បបរមា និងការដំឡើងប្រាក់ឈ្នួលដូចមានចែងក្នុងចំណុចទី១ ទី២ និងទី៣ ខាងលើ ត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៤ តទៅ។

II. ការផ្តល់អត្ថប្រយោជន៍ផ្សេងៗដែលធ្លាប់បានអនុវត្តកន្លងមក

១-ផ្តល់ប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅចំនួន ៧ (ប្រាំពីរ) ដុល្លារ ក្នុងមួយខែ។

ចំពោះកម្មករនិយោជិតណាដែលនិយោជកបានផ្តល់មធ្យោបាយធ្វើដំណើរ ឬផ្តល់កន្លែងស្នាក់នៅ គឺមិនត្រូវទទួលបាននូវប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅនេះទេ។ បើនិយោជកណាបានផ្តល់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅល្អប្រសើរជាងការកំណត់នេះ ត្រូវរក្សានៅដដែល។

២-កម្មករនិយោជិត ដែលបានមកធ្វើការទៀងទាត់តាមចំនួនថ្ងៃនៃថ្ងៃធ្វើការក្នុងខែនីមួយៗ ដោយគ្មានអវត្តមាន ត្រូវទទួលបានប្រាក់រង្វាន់យ៉ាងតិចចំនួន ១០ (ដប់) ដុល្លារក្នុងមួយខែ។

ចំពោះរោងចក្រ សហគ្រាស គ្រឹះស្ថានណាដែលបានផ្តល់ប្រាក់រង្វាន់លើសពីការកំណត់នេះត្រូវរក្សាប្រាក់រង្វាន់ដែលឱ្យលើសនោះនៅដដែល។

៣-កម្មករនិយោជិតដែលស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោង តាមសំណូមពររបស់និយោជកត្រូវទទួលបានប្រាក់ថ្លៃបាយចំនួន ២០០០ (ពីរពាន់) រៀលក្នុងមួយថ្ងៃ ឬទទួលបានការផ្តល់ជូនបាយមួយពេលដោយឥតគិតថ្លៃ។

៤-ប្រាក់រង្វាន់អតីតភាពការងារ

ក-កម្មករនិយោជិតដែលបានធ្វើការនៅក្នុងរោងចក្រ សហគ្រាស គ្រឹះស្ថានណាមួយលើសពីមួយឆ្នាំឡើងទៅ ត្រូវទទួលបានប្រាក់រង្វាន់អតីតភាពការងារ ដូចមាននៅក្នុងតារាងខាងក្រោមនេះ៖

អតីតភាពការងារគិតជាឆ្នាំ	១	២	៣	៤	៥	៦	៧	៨	៩	១០	១១
ចំនួនទឹកប្រាក់ទទួលបានក្នុងមួយខែគិតជាដុល្លារ	០	២	៣	៤	៥	៦	៧	៨	៩	១០	១១

ខ-កម្មករនិយោជិតដែលមានអតីតភាពការងារនៅឆ្នាំណា ត្រូវទទួលបានប្រាក់រង្វាន់អតីតភាពការងារនៅឆ្នាំនោះ (ដូចតារាងខាងលើ) លើកលែងតែកម្មករនិយោជិតដែលមានអតីតភាពការងារលើសពី ១១ ឆ្នាំឡើងទៅ ត្រូវទទួលបានប្រាក់រង្វាន់អតីតភាពការងារនៅក្នុងឆ្នាំទី១១ គឺចំនួន ១១ (ដប់មួយ) ដុល្លារក្នុងមួយខែ ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា អង្គការសហជីពគ្រប់ថ្នាក់ សមាគមនិយោជក កម្មករនិយោជិត និងនិយោជកនៃវាងចក្រ សហគ្រាសគ្រឹះស្ថាន ផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែងជើងទាំងអស់ នឹងអនុវត្តតាមសេចក្តីណែនាំនេះបានល្អប្រសើរ និងធានាបាននូវប្រសិទ្ធិភាពខ្ពស់។

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ ឆក្ក ឆ្នាំ២០១៤

រដ្ឋមន្ត្រី

អ៊ិត សំហេង

ចម្លងជូន:
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋមន្ត្រីប្រចាំការ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
"ដើម្បីជូនជ្រាប"
-គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត
-គ្រប់សមាគមនិយោជក
-គ្រប់សហព័ន្ធសហជីព
"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ